雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团

# ប្រទេសចិន-ខេត្តយូនណាន

ទស្សនាវដ្ដីប្រចាំថ្ងៃ

YUNNANEXPRESS
english.yunnan.cn

ឆ្នាំទី 24 លេខ 6975 ថ្ងៃសុក្រ ទី 11 ខែមីនា ឆ្នាំ 2016

## ពិព័រណ៍ចិន-អាស៊ីខាងត្បូង លើកទី៤នឹងបើកឡើងនៅទីក្រុងគុនមីញពីថ្ងៃទី១២ដល់១៧ខែមិថុនា

***ឈូ ស៊ូនីង***

កាលពីថ្ងៃទី១ ខែមីនា ក្រសួងពាណិជ្ជកម្មចិន និងរដ្ឋាភិបាលខេត្តយូនណានបានរៀបចំនូវសន្និសីទផ្សព្វផ្សាយនៃពិព័រណ៍អន្តរជាតិចិន-អាស៊ីខាងត្បូងលើកទី៤ និងពិព័រណ៍អន្តរជាតិទីក្រុងគុនមីញលើកទី២៤ នៅទីក្រុងប៉េកាំង។

ក្នុងសន្និសីទនេះបានប្រកាសថា ពិព័រណ៍អន្តរជាតិចិន-អាស៊ីខាងត្បូងលើកទី៤ និងពិព័រណ៍អន្តរជាតិទីក្រុងគុនមីញលើកទី២៤ នឹងធ្វើឡើងនៅក្នុងទីក្រុងគុនមីញនាថ្ងៃទី១២ដល់ថ្ងៃទី១៧ខែមិថុនាឆ្នាំនេះ។

ពិព័រណ៍ចិន-អាស៊ីខាងត្បូងឆ្នាំនេះ នឹងរៀបចំឡើងដោយយោងទៅតាមគំនិតអភិវឌ្ឍន៍ "ការច្នៃប្រឌិតថ្មី ភាពសម្របសម្រួលបៃតង ការបើកចំហ ការចែករំលែកគ្នា ការសហការគ្នា និងការទទួលជោគជ័យ" ជាប្រធានបទ ហើយយក "ការជំរុញការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការដ៏ពេញលេញរវាងចិននិងអាស៊ីខាងត្បូង" ជាគោលដៅ។ ពិព័រណ៍អន្តរជាតិលើកនេះនឹងមានទំហំតាំងពិព័រណ៍ដល់ទៅ១៧០.០០០ម៉ែត្រក្រឡា និងមានកន្លែងតាំងពិព័រណ៍ដល់ចំនួនជាង ៨.០០០។ ទំហំតាំងពិព័រណ៍និងចំនួនកន្លែងតាំងពិព័រណ៍ នឹងកើនឡើង៣៨ភាគរយ និង៣០ភាគរយបើធៀបនឹងពិព័រណ៍ចិន-អាស៊ីខាងត្បូងលើកទី៣ ដោយចំនួនកន្លែងតាំងពិព័រណ៍សម្រាប់បរទេស គឺលើសជាង៥០ភាគរយ។

ក្រៅពីការតាំងពិព័រណ៍ ការពិភាក្សាពាណិជ្ជកម្ម និងការចុះហត្ថលេខាក្នុងពិព័រណ៍ចិន-អាស៊ីខាងត្បូងឆ្នាំនេះ នឹងមានសកម្មភាពផ្សេងទៀតជាច្រើនដូចជា: វេទិកាពាណិជ្ជកម្មចិន-អាស៊ីខាងត្បូងលើកទី១១ វេទិកាបណ្ណាល័យបញ្ញាចិន-អាស៊ីខាងត្បូងលើកទី៤ សប្ដាហ៍សកម្មភាពនៃវេទិកាច្រករបៀងសេដ្ឋកិច្ច GMS សម័យទី៨ សប្ដាហ៍សិល្បៈចិន-អាស៊ីខាងត្បូង-អាស៊ីអាគ្នេយ៍។ល។

នៅក្នុងផែនការយុទ្ធសាស្ត្រ "ខ្សែក្រវាត់មួយផ្លូវមួយ" ប្រទេសចិន "ខេត្តយូនណានគឺជាខេត្តសំខាន់ជាងគេនៃប្រទេសចិនក្នុងការកសាងនៃច្រករបៀងសេដ្ឋកិច្ចបង់ក្លាដែសចិន-ឥណ្ឌា-ភូមា និងច្រករបៀងចិន-ជ្រោយឥណ្ឌូចិន។ សព្វថ្ងៃនេះ ខេត្តយូនណានបានក្លាយជាខេត្តគួរឱ្យទាក់ទាញជាងគេនៃប្រទេសចិនក្នុងវិស័យសេដ្ឋកិច្ច មានពាណិជ្ជករកាន់តែច្រើនឡើងៗមកស្វែងរកឱកាសពាណិជ្ជកម្មនិងវិនិយោគនៅខេត្តយូនណាន ។

លោកលី ជីហឹង លេខាធិការគណបក្សខេត្តយូនណានបានថ្លែងក្នុងសន្និសីទផ្សព្វផ្សាយថា ភាពជោគជ័យនៃពិព័រណ៍ចិន-អាស៊ីខាងត្បូងសម័យទាំង៣មុននោះ បានកសាងវេទិកាដ៏ល្អបំផុតមួយសម្រាប់ការផ្លាស់ប្តូរគ្នារវាងចិន និងអាស៊ីខាងត្បូង និងប្រទេសជាច្រើនទៀត ក្នុងវិស័យពាណិជ្ជកម្ម ការទូត វប្បធម៌ និងសិល្បៈ។ ពិព័រណ៍អន្តរជាតិចិន-អាស៊ីខាងត្បូងកំពុងក្លាយជាពិព័រណ៍អន្តរជាតិជាសកលដ៏មានទ្រង់ទ្រាយធំមួយ ដែលកសាងរួមគ្នានូវ "ខ្សែក្រវាត់មួយផ្លូវមួយ" ហើយព្រមទាំងមានកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម កិច្ចសហប្រតិបត្តិការផលិតកម្ម ការច្នៃប្រឌិតថ្មី សេវាកម្មហិរញ្ញវត្ថុ និងការផ្លាស់ប្តូរវប្បធម៌។

មន្ត្រីការទូតជាង៨០នាក់ ដែលមកពី ៣៩ប្រទេសនៃអាស៊ីខាងត្បូង-អាស៊ីអាគ្នេយ៍ និងទ្វីបអឺរ៉ុបអាហ្វ្រិក និងអាមេរិក បានចូលរួមសន្និសីទផ្សព្វផ្សាយលើកនេះ ។ ពួកគេបានសម្តែងថា បន្ទាប់ពីបានទទួលភាពជោគជ័យនៃពិព័រណ៍ចិនអាស៊ីខាងត្បូងទាំង៣លើកមុននោះ ពិព័រណ៍ចិន-អាស៊ីខាងត្បូងបានមានឥទ្ធិពលកាន់តែខ្លាំងឡើងនៅក្នុងប្រទេសជុំវិញ ហើយបានជំរុញកិច្ចសហប្រតិបត្តិការគ្នាមិនឈប់ឈរ។ ប្រទេសនានានឹងចូលរួមពិព័រណ៍ចិន-អាស៊ីខាងត្បូងលើកទី៤ខាងមុខនេះ ក្នុងរបៀបផ្សេងៗ ពួកមន្ត្រីការទូតក៏ជូនពរពិព័រណ៍ចិន-អាស៊ីខាងត្បូងឱ្យទទួលនូវជោគជ័យកាន់តែច្រើនទៀត៕

## គុនមីញបានរៀបចំការប្រកួតពាក់កណ្ដាលម៉ារ៉ាតុងលើខ្ពង់រាបអន្តរជាតិ



*អត្តពលិកប្រមាណជា ១៨.០០០នាក់ចូលរួមការរត់ពាក់កណ្ដាលម៉ារ៉ាតុននៅក្នុងទីក្រុងគុនមិញ រដ្ឋធានីនៃខេត្តយូនណានភាគនិរតីនៃប្រទេសចិន (ថតដោយ Lin Yiguang)*

***ដោយ : ហូ ធាងធាង***

កាលពីថ្ងៃទី២៨ ខែកុម្ភៈ កន្លងទៅ ធនាគារកសិកម្មចិនបានរៀបចំការប្រកួតពាក់កណ្ដាលម៉ារ៉ាតុងលើខ្ពង់រាបអន្តរជាតិឆ្នាំ២០១៦ នៅវិមានប្រជុំហៃគឿង ទីក្រុងគុនមីញ ដោយមានកីឡាករជាង១៨.០០០នាក់បានចូលរួម ។

នេះជាការប្រារព្ធពិធីប្រកួតម៉ារ៉ាតុងលើកទី១ក្នុងនិទាឃរដូវ ដោយការរត់នេះមានប្រវែង២១,០៩គីឡូម៉ែត្រ ។

លោកឃីម៉ានញូល ដែលមកពីប្រទេសតង់ហ្សានីបានឈ្នះជើងឯកក្រុមបុរសដែលអាចរត់នៅក្នុងថិរវេលា១ម៉ោង៤នាទី និង២វិនាទី ហើយបានបំបែកកំណត់ត្រាការប្រកួតនេះ ។ អ្នកនាងរ៉េបេខា ដែលមកពីប្រទេសកេនយ៉ា បានឈ្នះជើងឯកក្រុមស្រីដែលអាចរត់បាននៅក្នុងថិរវេលា១ម៉ោង១២នាទី និង៥៧វិនាទី ។

ការប្រកួតលើកនេះគឺជាការប្រកួតពាក់កណ្ដាលម៉ារ៉ាតុងលើកទី១ ដែលចាប់ផ្ដើមពីក្នុងទីក្រុង ហើយជាលើកទី១ ដែលមាន CCTV5 មកផ្សាយបន្តផ្ទាល់នៅលើផ្លូវប្រកួត ដែលមានអ្នកណែនាំផ្លូវក្នុងគ្រប់គីឡូម៉ែត្រដែលបានពាក់សម្លៀកបំពាក់ជនជាតិភាគតិច អ្នកស្ម័គ្រចិត្ត អ្នកផ្ដល់សេវាកម្មដោយស្លៀកពាក់សម្លៀកបំពាក់សុទ្ធតែជារបស់ជនជាតិភាគតិច ។

នៅទីបំផុតលោកឃីម៉ានញូល ដែលមកពីប្រទេសតង់ហ្សានី លោកគីភ ថុយធូិន ដែលមកពីប្រទេសកេនយ៉ា និងលោកធឹស ក្យា ដែលមកពីប្រទេសអេត្យូពី បានឈ្នះរង្វាន់ទី១ ដល់ទី៣ នៃក្រុមបុរស ។ អ្នកនាងរ៉េបេខា និងអ្នកនាងការ៉ូលីន ដែលមកពីប្រទេសកេនយ៉ា បានឈ្នះរង្វាន់ទី១ និងទី៣ នៃក្រុមស្រី អ្នកនាងចាំង ឌឺសួន ដែលមកពីខេត្តយូនណាន បានឈ្នះរង្វាន់ទី២ ហើយបានទទួលពិន្ទុល្អជាងគេក្នុងជីវិតកីឡារបស់ខ្លួនឯង ។ ក្នុងការប្រកួត១២គីឡូម៉ែត្រក្រុមបុរស លោកលីក្វាន់ភីង លោកឈូវីយ និងលោកលីសាវច្វាំង មកពីប្រទេសចិន បានឈ្នះរង្វាន់ទី១ដល់ទី៣ ។ ក្នុងការប្រកួត១២គីឡូម៉ែត្រក្រុមស្រី អ្នកនាងឆឹនហុងមីយ និងអ្នកនាងថាងស្យ៉ា បានឈ្នះរង្វាន់ទី១ និងទី៣ ហើយអ្នកនាងយីវ៉ា ខ្វឹក បានឈ្នះរង្វាន់ទី២ ៕

## "នេះជាលើកទីមួយដែល ខ្ញុំបានជិតនឹងឪពុកខ្ញុំ"



*លោកស្រី ជូឌី បានទៅទស្សនាដល់បុរាណដ្ឋាននៃព្រលានយន្តហោះយ៉ាងជៀ ស្ថិតនៅខេត្តយូនណាន ភាគនិរតីនៃប្រទេសចិន (ថតដោយ Liu Ziyu )*

***ដោយ : លីវ ជឺយូ***

លោកស្រីជូឌី កូនចៅនៃទាហាន "ក្រុមខ្លាហោះ" បានទស្សនាស្នាមជើងប្រវត្តិសាស្ត្ររបស់ឪពុក "ខ្ញុំរំភើបចិត្តណាស់! សូមអរគុណដល់អ្វីទាំងអស់ដែលអ្នកទាំងអស់គ្នាធ្វើចំពោះឪពុកខ្ញុំ!" ។ ថ្ងៃទី២២ និង២៣ លោកស្រីជូឌី អេកេស កូនស្រីនៃលោកវ៉េលាម វ៉ាឡេស សមាជិកនៃ "ក្រុមក្លាហោះ" និងប្ដីរបស់លោកស្រីបានមកដល់ស្រុកឃីលាំង និងស្រុកសុងមីង នៃទីក្រុងគុនមីញ ដើម្បីរំលឹកវិញ្ញាណក្ខន្ធដល់ឪពុកលោកស្រី ។

ពីភូមិឈាងស្វួយថាង ដល់វិមានរំលឹករបស់លោកវ៉េលាមវ៉ាឡេស ត្រូវឆ្លងកាត់ផ្លូវភ្នំមួយដែលត្រូវដើរ ៣០នាទី ។ ពេលទើបបានឃើញវិមានរំលឹកទឹកភ្នែករបស់លោកស្រីជូឌីក៏ធ្លាក់ចុះដោយឃាត់មិនបាន ។ "ខ្ញុំមិនដែលឃើញឪពុកខ្ញុំទេ នេះជាលើកទី១ ដែលខ្ញុំបានជិតនឹងឪពុកខ្ញុំ! ខ្ញុំកើតឡើងនៅប្រទេសអាមេរិកតាំងពីកុមារខ្ញុំក៏ដឹងថាឪពុកខ្ញុំជាវីរបុរសម្នាក់ មិនគិតដល់ថានៅប្រទេសចិន គេក៏ទុកឪពុកខ្ញុំជាវីរបុរសដែរ ។" បន្ទាប់ពីភាពស្ងៀមស្ងាត់អស់រយៈពេលបីនាទី លោកស្រីជូឌី បានដាក់ផ្កាស្រស់នៅមុខវិមានរំលឹក ។

វិមានរំលឹកវ៉ាឡេស មានទម្ងន់មួយតោន ដែលត្រូវសាងឡើងដោយលោកចូវ ជូស៊ានន មនុស្សខេត្តគួយចូវម្នាក់ និងជនជាតិអាមេរិកលោកល្វីប៉េយ ដែលជាសមាជិកម្នាក់នៃ "ការចែករំលែករុងរឿង" ដែលជាអង្គការសង្គមស៊ីវិលមួយ អង្គការសង្គមស៊ីវិលនេះយកការស្រាវជ្រាវចំពោះប្រវត្តិសាស្ត្រសហការចិន-អាមេរិកក្នុង សង្គ្រាមលោកលើកទី២ជាគោលដៅ ។ នៅខែកញ្ញា ឆ្នាំមុន លោកល្វីប៉េយបានទាក់ទងដល់លោកស្រីជូឌី ហើយបានចាប់ផ្ដើមរៀបចំឱ្យលោកស្រីមកទស្សនានៅប្រទេសចិន ។

លោកលី ជុនហ្វា អ្នកស្រុកម្នាក់នៃភូមិឈាងស្វួយថាង ដែលធ្លាប់ចូលរួមការកសាងនៃវិមានរំលឹកនេះ បានណែនាំថា នៅពេលនោះយោងតាមទំនៀមទម្លាប់នៃការដាក់ឈ្មោះនៃភូមិឈាងស្វួយថាង គេបានដាក់ឈ្មោះចិនមួយឱ្យលោកវ៉េលាម វ៉ាឡេស ថា លីស្វួហ្វា ធ្វើឱ្យលោកវ៉េលាម វ៉ាឡេស ក្លាយជាសមាជិកម្នាក់នៃត្រកូលលី ។ ហេតុនេះលោកស្រីជូឌី គឺត្រូវជាបងស្រីរបស់គាត់ លើកនេះមានសាច់ញាតិមកដល់ភូមិខ្លួនពីទីឆ្ងាយ ធ្វើឱ្យលោកលី ជុនហ្វា សប្បាយចិត្តណាស់ ។ "ខ្ញុំក៏ធ្លាប់ធ្វើជាទាហានម្នាក់ ហេតុនេះខ្ញុំដឹងច្បាស់ណាស់ដែលសន្តិភាព និងជីវភាពដ៏មានសុភមង្គល វាមកពិតជាមិនងាយទេ" និយាយដោយលោកលី ជុនហ្វា ។

ប្ដីប្រពន្ធលោកស្រីជូឌីបានទស្សនាដល់បុរាណដ្ឋាននៃព្រលានយន្តហោះយ៉ាងជៀ ដែលធ្លាប់ធ្វើជាព្រលានយន្តហោះយោធានៅក្នុងសង្គ្រាមលោកលើកទី២ ហើយក៏បានជូនវត្ថុអនុស្សាវរីយ៍ទៅវិញទៅមកជាមួយនឹងអ្នកនៅរស់នៅដែលធ្លាប់កសាងព្រលានយន្តហោះនេះ ។ "ដើរមើលដោយផ្ទាល់ខ្លួន ហើយផ្លាស់ប្ដូរគ្នាជាមួយអ្នកស្រុកទីនេះ ធ្វើឱ្យខ្ញុំស្គាល់ឪពុកខ្ញុំដោយកាន់តែច្បាស់ ទន្ទឹមនឹងនេះខ្ញុំក៏រំភើបចិត្តណាស់ចំពោះការរាក់ទាក់ចិត្តល្អរបស់អ្នកស្រុក និងការការពារចំពោះប្រវត្តិសាស្ត្ររបស់ពួកគេ" ។

"ក្រុមខ្លាហោះ" គឺជា "ក្រុមយន្តហោះចិន និងអាមេរិក" ដែលមកចូលរួមសង្គ្រាមប្រឆាំងជប៉ុននៅប្រទេសចិន នាខែកក្កដា ឆ្នាំ១៩៤១ ។ លោកវ៉េលាម វ៉ាឡេស បានចូលរួមសង្គ្រាមប្រឆាំងជប៉ុននៅប្រទេសចិន នាចុងឆ្នាំ ១៩៤៣ នៅក្នុងឋានៈជាកាពីតែនយន្តហោះម្នាក់នៃយន្តហោះទម្លាក់គ្រាប់បែក B-24 មួយគ្រឿង ។ ខែមិថុនា ឆ្នាំ១៩៤៤ លោកវ៉េលាម វ៉ាឡេស បានស្លាប់ដោយសារការធ្លាក់យន្តហោះនៅពេលបំពេញភារកិច្ចនៅជិតនឹងភូមិឈាងស្វួយថាងនេះ នៅក្នុងវ័យត្រឹមតែ ២៥ឆ្នាំ ៕

## ប្រទេសចិនអនុម័តការបង្កើតតំបន់លើកលែងពន្ធជាសកលនៅទីក្រុងគុនមីញ

***ចាំង យ៉ានឈួន***

បច្ចុប្បន្ននេះ គណៈកម្មការកំណែទម្រង់ និងអភិវឌ្ឍន៍ជាតិរបស់ប្រទេសចិនបានប្រកាសថា ក្រុមប្រឹក្សារដ្ឋរបស់ប្រទេសចិនបានអនុម័តថា ធ្វើសមាហរណកម្មតំបន់កែច្នៃនាំចេញទីក្រុងគុនមីញ និងទីក្រុងណានឆាង ជាតំបន់លើកលែងពន្ធជាសកល ។

តំបន់លើកលែងពន្ធជាសកលគឺជាតំបន់ពិសេសមួយដែលស្ថិតក្នុងប្រទេសចិន ដែលមានតួនាទីជាតំបន់កំពង់ផែ តំបន់កែច្នៃនាំចេញ តំបន់ដឹកជញ្ជូនអន្តរជាតិជាដើម ហើយស្ថិតក្រោមការត្រួតពិនិត្យពីគយចិន និងត្រូវដំណើរការដោយយោងតាមនយោបាយពន្ធ និងនយោបាយរូបិយ-ប័ណ្ណបរទេសចិន។

តំបន់លើកលែងពន្ធជាសកលទីក្រុងគុនមីញ គឺជាតំបន់លើកលែងពន្ធជាសកលទី១នៃខេត្តយូនណាន បន្ទាប់ពីតំបន់លើកលែងពន្ធជាសកលរដ្ឋហុងហឺង ខេត្តយូនណាន ។ តំបន់លើកលែងពន្ធជាសកលទីក្រុងគុនមីញ ចែកជាតំបន់A និងតំបន់B ។ តំបន់A គឺស្ថិតនៅតំបន់កែច្នៃនាំចេញទីក្រុងគុនមីញ ដែលមានទំហំ០,៥៨គីឡូម៉ែត្រក្រឡា ឥឡូវបានចាប់ផ្ដើមដំណើរការហើយ។ តំបន់B នឹងត្រូវកសាងនៅជិតនឹងព្រលានយន្តហោះទីក្រុងគុនមីញ ដែលនឹងមានទំហំ១,៤២គីឡូម៉ែត្រក្រឡា។ តំបន់ A នឹងក្លាយជាតំបន់សំខាន់សម្រាប់អភិវឌ្ឍន៍ឧស្សាហកម្មនានាដែលមានលក្ខណៈពិសេសនៃខេត្តយូនណាន និងប្រទេសជិតខាងដូចជា ឧស្សាហកម្មធនធានគ្រឿងអលង្ការ ឧស្សាហកម្មជីវឱសថ និងឧស្សាហកម្ម អាហារ ។ រីឯតំបន់B នឹងក្លាយជាតំបន់សំខាន់សម្រាប់ការអភិវឌ្ឍពាណិជ្ជកម្ម (entrepot) ឃ្លាំងស្តុកនិងការកែច្នៃជាដើម ៕